# របាយការណ៍លទ្ធផលការងារឆ្នាំ២០២២
# និងលើកទិសដៅការងារឆ្នាំ២០២៣ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប

## សេចក្តីផ្តើម

### ស្ថានភាព ទូទៅរបស់ខេត្តសៀមរាប

ខេត្តសៀមរាប ស្ថិតនៅភូមិភាគពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជាតាមបណ្តោយផ្លូវជាតិលេខ៦ មានចម្ងាយផ្លូវ ប្រវែង ៣១៤គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មាន ០១ក្រុង ១១ស្រុក ១២សង្កាត់ ៨៨ឃុំ ស្មើនឹង ៩៥២ភូមិ និងភូមិផ្លូវការ ៩១០(ភូមិ)។ ប្រជាពលរដ្ឋទាំងអស់សរុបចំនួន ១.១៦៦,៤៩៣នាក់ ក្នុងនោះមានស្ត្រី ចំនួន ៥៩០.១៥៤នាក់ និងមានគ្រួសារសរុបចំនួន ២៥០.៦៦២គ្រួសារ។ មានទំហំផ្ទៃដីសរុប ១០.២៩៩,៤៣ គីឡូម៉ែត្រក្រឡា និងមានដង់ស៊ីតេ ១០៨.១នាក់/គីឡូម៉ែត្រក្រឡា (CDB 2021)។ មានព្រំប្រទល់៖

- ខាងជើងទល់ និងខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ
- ខាងត្បូងទល់ និងខេត្តបាត់ដំបង និងបឹងទន្លេសាប
- ខាងកើតទល់ និងខេត្តកំពង់ធំ និង ខេត្តព្រះវិហារ
- ខាងលិចទល់ និងខេត្តបន្ទាយមានជ័យ

## I.សមិទ្ធផលសម្រេចបាន

### ១.ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

#### ការងាររដ្ឋបាល និងបុគ្គលិក

- បានទទួលលិខិតចូលពីបណ្តាស្ថាប័នចំនួន ២៧៤លិខិត
- បានទទួលលិខិតចូលពីក្រសួងចំនួន ៨៣លិខិត
- បានផ្ញើលិខិតចេញទៅអង្គភាពនានា ចំនួន ១៦៤លិខិត
- បានផ្ញើលិខិតចេញទៅសាលាខេត្តចំនួន ៤៦លិខិត
- បានផ្ញើលិខិតអញ្ជើញចំនួន ០៨លិខិត
- បានផ្ញើលិខិតទៅក្រសួង និងនាយកដ្ឋានចំនួន ១៣១លិខិត
- បានផ្ញើលិខិតផ្ទេរសិទ្ធចំនួន ០៥លិខិត
- បានរៀបចំរបាយការណ៍បៀវត្សន៍មន្ត្រីរាជការស៊ីវិល១២ខែ ឆ្នាំ២០២២។
- បានសម្របសម្រួលចុះលេខលិខិតចេញ-ចូល ជាប្រចាំ សម្រាប់មន្ទីរ ។
- បានរៀបចំឯកសារបេសកកម្មជូនថ្នាក់ដឹកនាំមន្ទីរថ្នាក់ដឹកនាំការិយាល័យ និងមន្ត្រីរាជការនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប តាមការចាត់តាំងជាប្រចាំ។

- បានសម្របសម្រួលបញ្ជីវត្តមានប្រចាំថ្ងៃរបស់មន្ត្រីរាជការ ដើម្បីផ្ញើជូនក្រសួង និងខេត្ត
- បានចុះជួយរៀបចំរបាយការណ៍ស្រង់ទិន្នន័យក្រុមចត្តាឡីស័កនៅក្នុងខេត្តសៀមរាប។
- បានចូលរួមពិធីសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ តាមរយៈប្រព័ន្ធវីដេអូ ZOOM
- បានរៀបចំរបាយការណ៍វេទិកាសាធារណៈ ជូនក្រសួងអភិវឌ្ឍន៍ជនបទ។
- បានចូលរួមកិច្ចប្រជុំសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាខេត្តនៅសាលាខេត្ត
- បានចូលរួមកិច្ចប្រជុំត្រួតពិនិត្យលទ្ធផលការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានស្រុកស្វាយលើដើម្បីពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយនៅសាលាស្រុកស្វាយលើ។
- បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី៣០ ប្រចាំឆ្នាំ២០២១ របស់គណៈកម្មាធិការពិគ្រោះយោបល់ និងកុមារ ( គ ក ស ក) ខេត្ត អាណត្តិទី៣ នៅសាលាខេត្ត។
- បានចូលរួមកិច្ចប្រជុំត្រួតពិនិត្យលើការរៀបចំរបាយការណ៍សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ រដ្ឋបាលខេត្តសៀមរាប។
- បានចូលរួមកិច្ចប្រជុំប្រចាំខែមករា និងខែកុម្ភៈ ឆ្នាំ២០២២ របស់គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) នៅសាលាខេត្តសៀមរាប ។
- បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី៣២ ប្រចាំខែកុម្ភៈ ឆ្នាំ២០២២ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ(គ.ក.ស.ក) ខេត្តអាណត្តិទី៣ នៅសាលាខេត្តសៀមរាប។
- បានជួបសំណេះសំណាលការងារជាមួយអង្គការទស្សនៈពិភពលោកដើម្បីជម្រាបជូនអំពីរបាយការណ៍ការងារប្រចាំឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ នៅសាលាខេត្តសៀមរាប។
- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយការចងក្រងសមាជិកចលនាភូមិមួយផលិតផលមួយ និងប្រគល់វិញ្ញាបនបត្រ នៅសាលាខេត្តសៀមរាប។
- បានចូលរួមកិច្ចប្រជុំសម្របសម្រួលស្តីពីការអនុវត្តផែនការកិច្ចការពារកុមារខេត្តប្រចាំត្រីមាសទី១ ឆ្នាំ២០២២ នៅសាប្រជុំធំសាលាខេត្តសៀមរាប
- បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី៣៣ប្រចាំខែមីនា និងប្រចាំត្រីមាសទី១ ឆ្នាំ២០២២ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) ខេត្ត អាណត្តិទី៣ នៅសាលាខេត្តសៀមរាប
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការប្រើប្រាស់ឯកសារព័ត៌មានស្ថានភាព សេដ្ឋកិច្ចសង្គមកិច្ច ឯកសារព័ត៌មានពិន្ទុវិស័យ និងអត្រាភាពក្រីក្រខេត្ត ក្រុង ស្រុកឆ្នាំ២០២២ សម្រាប់ដំណើរការកសាងផែនការនៅថ្នាក់ខេត្ត ក្រុង ស្រុក នៅបន្ទប់ប្រជុំមន្ទីរ ផែនការខេត្តសៀមរាប។
- បានចូលរួមជាគណៈអធិតីក្នុងពិធីប្រកាសជាផ្លូវការឃុំបញ្ឈប់បន្ទោបង់ពាសវាលពាសកាល១០០% នៅឃុំជ្រោយនាងងួង ស្រុកស្រីស្នំ

- បានចូលរួមពិធីសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ តាមរយៈប្រព័ន្ធវីដេអូ ZOOM
- បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី៣៥ របស់ក្រុមប្រឹក្សាខេត្តអាណត្តិទី៣ នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ តាមរយៈប្រព័ន្ធវីដេអូអនឡាញ Zoom Meeting។
- ពិធីដាក់ប្រកាសឱ្យដំណើការអនុក្រឹត្យស្តីពីគណៈកម្មាធិការពិសេសតាមដានការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិ ស្តីពី ប្រជាជន និងអភិវឌ្ឍន៍ និងប្រកាសសមាសភាពនៃគណៈកម្មាធិការពិសេសនេះ តាមរយៈប្រព័ន្ធវីដេអូអនឡាញ Zoom Meeting ។
- បានអញ្ជើញចូលរួមជាគណៈអធិបតី ក្នុងកម្មវិធីទិវាទឹកពិភពលោក ក្រោមប្រធានបទ "ទឹកក្រោមដី" ដើម្បីបង្កើនការយល់ដឹង និងថែរក្សាប្រភពទឹកក្រោមដី របស់សហគមន៍ប្រកបដោយចីរភាព នៅឃុំស្លែងស្ពាន និងឃុំស្រែខ្វាវ។
- បានចូលរួមពិធីបើកសម្ភោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ សួនរុក្ខជាតិអង្គរក្រោមអធិបតីភាពឯកឧត្តមជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានចូលរួមកិច្ចប្រជុំប្រចាំខែឧសភា ឆ្នាំ២០២២ របស់កម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្ស នៅសាលាខេត្តសៀមរាប
- បានអញ្ជើញចូលរួមពិធីចូលកាន់មុខតំណែងប្រធានមន្ទីរសង្គមកិច្ចអតីតយុទ្ធជននិងយុវនិតិសម្បទា នៅសាលាខេត្តសៀមរាប
- បានអញ្ជើញចូលរួម សំណេះសំណាលការងារស្តីពី សុវត្ថិភាពស្បៀងអាហារ ក្នុងខេត្តសៀមរាប ជាមួយអង្គការ AGISUD INTERNATIONAL
- បានចូលរួមសិក្ខាសាលាស្តីពី ការរៀបចំយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៣-២០២៥ និងថវិកាសមិទ្ធកម្មឆ្នាំ២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅថ្ងៃ១៧ ខែមិថុនា ឆ្នាំ២០២៣ នៅខេត្តព្រះសីហនុ។
- បានចូលរួមកម្មវិធីស្តីពីការផ្សព្វផ្សាយលទ្ធផល នៃការអនុវត្តថវិកាកម្មវិធី របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារខេមរាអង្គរ និងស្ប៉ា ខេត្តសៀមរាប
- បានចូលរួមកិច្ចប្រជុំស្តីពី ការងារអភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច ប្រចាំឆមាសទី០១ ឆ្នាំ ២០២២ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមកិច្ចប្រជុំប្រចាំឆមាសទី១ ឆ្នាំ២០២២ របស់លេខាធិការដ្ឋានគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងនៅបន្ទប់ប្រជុំសាលាខេត្ត។
- បានចូលរួមកិច្ចប្រជុំស្តីពី ការងារអភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច ប្រចាំឆមាសទី០១ ឆ្នាំ ២០២២ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមបណ្តុះបណ្តាល ស្តីពីការប្រតិបត្តិ និងការអនុវត្តលើលក្ខណៈបច្ចេកទេស ក្នុងការថែទាំស្ថានីយចែកចាយទឹក នៅស្រុកជីក្រែងខេត្តសៀមរាប
- បានចូលរួមសម្របសម្រួលសិក្ខាសាលា ស្តីពីការងារស្ថិតិយេនឌ័រលើកទី៣ ដើម្បីវាយតម្លៃបញ្ចប់គម្រោង និងកិច្ចប្រជុំក្រុមការងារ WEE នៅសាលាខេត្តសៀមរាប

- បានចូលរួមសិក្ខាសាលាស្តីពីការពង្រឹងប្រសិទ្ធភាពនៃការបន្ថយការលេចធ្លាយប្រាក់ចំណូលពីការប្រើប្រាស់ផលិតផលរ៉ែសំណង់សម្រាប់គម្រោងអភិវឌ្ឍន៍ នៅអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែ និងថាមពល រាជធានីភ្នំពេញ។
- បានចូលរួមក្នុងកម្មវិធីសម្ពោធបើកដំណើរការគម្រោង ទឹកជាជីវិតប្រចាំខេត្តសៀមរាប វគ្គ៣ ដែលឧបត្ថម្ភជំនួយពីប្រទេសសិង្ហបុរី នៅឃុំស្វាយសស្រុកសូទ្រនិគម ខេត្តសៀមរាប
- បានចូលរួមប្រកាសភូមិ ដែលបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល របស់អង្គការ life water នៅឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប។
- បានចូលរួមកម្មវិធីវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ក្រុមប្រឹក្សាអាណត្តិទី៣ ឆ្នាំ ២០២២ នៅស្រុកវ៉ារិន ស្រុកជីក្រែង ស្រុកអង្គរធំ ស្រុកអង្គរជុំ និងស្រុកបន្ទាយស្រី។
- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី លទ្ធផល នៃការវាយតម្លៃបញ្ច្រៀបភាពធន់នឹងអាកាសធាតុក្នុងកម្មវិធីទឹកស្អាត និងអនាម័យនៅសណ្ឋាគារខេមរាអង្គរខេត្តសៀមរាប
- បានចូលរួមព្រឹត្តិការណ៍ដើរបញ្ឈប់អំពើជួញដូរមនុស្ស នៅមុខមហាសណ្ឋាគារអង្គរ ក្រោមអធិបតីភាព ឯកឧត្តម ទៀ សីហា អភិបាលនៃគណៈអភិបាលខេត្តសៀមរាប
- បានចូលរួមកម្មវិធីសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកឃុំ ឆ្នាំ២០២៣-២០២៥ នៅស្រុកពួក ស្រុកវ៉ារិន ស្រុកបន្ទាយស្រី ស្រុកអង្គរធំ ស្រុកសូទ្រនិគម និងស្រុកអង្គរជុំ
- បានចូលរួមពិធីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ គម្រប់ខួប១០ឆ្នាំ នៅព្រះរាជដំណាក់ ខេត្តសៀមរាប
- បានចូលរួមវេទិកានិងពិធីប្រគល់ពានរង្វាន់សហគ្រិនស្រ្តីអាស៊ាន អមព្រឹត្តិការណ៍នៃកិច្ចប្រជុំកំពូលស្រ្តីអាស៊ានលើកទី២ក្រោមប្រ ធានបទការកសាងអនាគតប្រកបដោយចីរភាពបរិយាប័ន្ន និងកាន់តែរឹងមាំ៖ បំផុសសហគ្រិនភាពរបស់ស្រ្តីក្នុងអាស៊ាននៅ សាលប្រជុំមន្ទីរកិច្ចការនារី
- បានចូលរួមពិធីបុណ្យកឋិនទានសាមគ្គី និងអភិសេកព្រះរូប នៅវត្តព្រះឥន្ទកោសីយ៍ ក្រោមអធិបតីភាព លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន
- បានចូលរួមជាគណៈអធិបតីក្នុងវគ្គសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីផែនការអភិវឌ្ឍន៍ឃុំស្រុក ក្នុងការលើកកម្ពស់អនាម័យជនបទដើម្បីអោយបានសម្រេចបានជាស្រុក ODF
- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយដាក់ឱ្យអនុវត្តផែនការសកម្មភាពគាំពារ និងការអភិវឌ្ឍន៍កុមារតូច ឆ្នាំ២០២២-ឆ្នាំ២០២៦ នៅសាលប្រជុំសណ្ឋាគារភ្នំពេញ

**ការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងអប់រំផ្សព្វផ្សាយដល់មន្ត្រីរាជការ**

- មជ្ឈមណ្ឌលបានបើក វគ្គបណ្តុះបណ្តាលជំនាញ សួនដំណាំគ្រួសារ និងជីកំប៉ុស្ត៍ ០១វគ្គ ក្នុងភូមិស្វាយស ឃុំស្វាយស ស្រុកវ៉ារិន ខេត្តសៀមរាបមានសិក្ខាកាមចំនួន ២៥នាក់ ស្រី២១ នាក់ និងវគ្គជួសជុលគ្រឿងយន្តកសិកម្មចំនួន០២វគ្គធ្វើនៅភូមិស្វាយជ័យ,ឃុំត្រពាំងធំនិងភូមិដូនទាវ ឃុំល្វេសស្រុកប្រាសាទបាគង ដែលមានសិក្ខាកាមចំនួន៤០នាក់ស្រី០២នាក់។
- មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន ខេត្តសៀមរាប បានចូលរួមប្រជុំនៅនាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ នៅក្រសួងអភិវឌ្ឍន៍ជនបទស្តីពី ការដឹកនាំ និងការគ្រប់គ្រងមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន ដើម្បីពិភាក្សាអំពី បញ្ហាប្រឈម សំណូមពរ ដំណោះស្រាយ ផែនការអនុវត្តបន្ត ការងាររៀបចំដំណើរការរបស់មជ្ឈមណ្ឌល ។
- មជ្ឈមណ្ឌលបានចុះផ្សព្វផ្សាយពីផែនការសម្រាប់ឆ្នាំ២០២៣ ជូនប្រជាពលរដ្ឋតាមភូមិ ឃុំ,ស្រុក គោលដៅដើម្បីឲ្យពួកគាត់ត្រៀមចូលរួមបើកវគ្គចំនួន ៣ជំនាញគឺមាន៖ ជំនាញជួសជុល និងថែទាំគ្រឿងយន្តកសិកម្ម, សួនដំណាំគ្រួសារ, និងជំនាញ ផលិតសាប៊ូលាងចាន។ ពិសេសចំពោះជំនាញផលិតសាប៊ូលាងចានត្រូវបានសហការជាមួយនឹងការិយាល័យអភិវឌ្ឍន៍សហគមន៍របស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តសៀមរាប និងសាលាខេត្តសៀមរាប បានផ្តួចផ្តើមបង្កើតឲ្យបានជាភូមិមួយ ផលិតផលមួយ (ផលិតសាប៊ូលាងចានតាមសហគមន៍) ។
- ត្រៀមធ្វើការស្នើសុំបើកវគ្គបណ្តុះបណ្តាលថ្មីតាមភូមិឃុំស្រុកគោលដៅជាមួយ អាជ្ញាធរមូលដ្ឋានដោយផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលមួយចំនួន រួមមាន៖ ជំនាញជួសជុល និងថែទាំគ្រឿងយន្តកសិកម្ម, សួនដំណាំគ្រួសារ, បច្ចេកទេស បណ្តុះផ្សិត, ភាសាអង់គ្លេស។

**ការងារផែនការ**

- ចូលរួមប្រជុំពិភាក្សាលើកការងារចុះសម្ភាសន៍ សម្រាប់អង្កេត ប្រមូល ចងក្រង វិភាគទិន្នន័យស្តីពីសេដ្ឋកិច្ច បរិស្ថានប្រចាំឆ្នាំ២០២២ ក្នុងខេត្តសៀមរាប។
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយដាក់ឱ្យអនុវត្តផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ឆ្នាំ២០២២-២០២៦។
- ចូលរួមសហមារណកម្មនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឆ្នាំ២០២៣-២០២៥ ស្រុក ឃុំនៅស្រុកស្រីស្នំ។
- ចូលរួមគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ ព្រះមហាវិរៈក្សត្រ ព្រះវររាជបិតា ឯករាជ្យបូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋគម្រប់ខួប ១០ឆ្នាំ ។
- បូកសរុបរបាយការណ៍ប្រចាំឆ្នាំ២០២២
- បានចុះប្រមូលទិន្នន័យតាមក្រុង-ស្រុកទាំង ១២ក្នុងខេត្ត សម្រាប់អនុវត្តគម្រោងកែលម្អ និងកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងស្ថិតិជនបទដើម្បីដាក់ចូល ក្នុងផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍ជនបទ (២០២១-២០៣០)។

- ចូលរួមកិច្ចប្រជុំ ស្ដីពី ការរៀបចំគម្រោងស្នើសុំហិរញ្ញប្បទាន ឥតសំណងពីរដ្ឋាភិបាលសាធារៈណរដ្ឋកូរ៉េ សម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០២៤ តាមប្រព័ន្ធវីដេអូ Microsoft Team
- ចូលរួមសិក្ខាសាលាស្ដីពី ការរៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ(ក.វ.ស) ៣ឆ្នាំរំកិល២០២៣-២០២៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ តាមប្រព័ន្ធអនឡាញ Zoom។
- ចូលរួមសិក្ខាសាលាបណ្ដុះបណ្ដាលគោលការណ៍ណែនាំ ស្ដីពី ការរៀបចំថវិកាព័ត៌មានសមិទ្ធកម្មរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- ចុះផ្ទៀងផ្ទាត់ភូមិបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាលចំនួន ១០ភូមិ នៅស្រុកក្រឡាញ់ ឃុំរពាងគោ ឃុំយាងស្រុកពួក ឃុំល្វាក្រាំងស្រុកវ៉ារិន។
- ចូលរួមសម្ភោធ និងប្រគល់មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ជូនដល់ប្រជាពលរដ្ឋនៅភូមិនាងស្រោង ឃុំត្រាំសសរ ស្រុកស្រីស្នំ
- ចូលរួមសិក្ខាសាលា ស្ដីពី ការជំរុញការអនុវត្តគោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០ ក្នុងគោលដៅក្របខ័ណ្ឌអភិវឌ្ឍន៍ប្រកបដោយចេរីភាពកម្ពុជា ប្រជាជន និងការអប់រំ។
- សិក្ខាសាលាស្ដីពីការរៀបចំសៀវភៅស្ថិតិយេនឌ័រនៅខេត្តសៀមរាប ។
- ចូលរួមកិច្ចប្រជុំស្ដីពីការវិភាគស្ថានភាពរៀបចំគម្រោងអាទិភាព ផ្នែកសេវាសង្គមសម្រាប់កម្មវិធីវិនិយោគបីឆ្នាំរំកិល និងផែនការយុទ្ធសាស្ត្រថវិកា របស់រដ្ឋបាលខេត្ត ឆ្នាំ២០២៣ - ២០២៥ ។
- ចូលរួមប្រជុំពិនិត្យ និងចាត់អាទិភាពគម្រោងសកម្មភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៣-២០២៥)របស់រដ្ឋបាលខេត្តសៀមរាប ។
- ចុះផ្ទៀងផ្ទាត់ឃុំបញ្ឈប់បន្ទោបង់ពាសវាលពាសកាល ចំនួន ០២ឃុំ (ឃុំល្វាក្រាំង និងឃុំប្រាសាទ) ដែលឃុំទាំង ០២នេះក្លាយជាឃុំ OFD។
- ចុះតាមដាននិងប្រជុំផ្សព្វផ្សាយ និងជ្រើសរើសទីតាំងអណ្ដូងថ្មី នៅស្រុកសូទ្រនិគម ស្រុកអង្គរជំ និងស្រុកវ៉ារិន។
- ចុះតាមដានការប្រជុំផ្សព្វផ្សាយដើម្បីរៀបចំក្រុមប្រើប្រាស់ទឹក និងអនាម័យ នៅស្រុកបន្ទាយស្រី។
- ចូលរួមសិក្ខាសាលារៀបចំផែការយុទ្ធសាស្ត្រថិវិកាឆ្នាំ ២០២៣-២០២៥ និងគម្រោងថវិកាឆ្នាំ២០២៣ លើវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ។
- ចូលរួមកិច្ចប្រជុំធ្វើបច្ចុប្បន្នភាពទិន្នន័យសហគមន៍ឆ្នាំ២០២២
- ចូលរួមវេទិការសាធារណៈនៅស្រុកស្រីស្នំ
- ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការផ្សព្វផ្សាយសហគមន៍តាមរយៈបណ្ដាញសង្គម សម្រាប់សហគមន៍ទេសចរណ៍គោលដៅ។

**ការងារផ្គត់ផ្គង់និងហិរញ្ញវត្ថុ**

- ធ្វើបញ្ជីទិន្នានុប្បវត្តិសៀវភៅធំ,បញ្ជីបេឡាបេសកកម្មទូទាត់ត្រង់,សៀវភៅសំរង់អាណត្តិ រៀបឯកសារទូទាត់បៀវត្សមន្ត្រីរាជការ និងមន្ត្រីកិច្ចសន្យា ពីខែសីហា-ធ្នូ ក្នុងឆ្នាំ២០២២

- រៀបចំរបាយការណ៍សម្រេចទូទាត់ សម្រាប់ឆ្នាំ២០២១ ឆ្នាំ២០២២
- រៀបចំរបាយការណ៍កិច្ចលទ្ធកម្ម ប្រចាំឆ្នាំ២០២២
- រៀបចំឯកសារផ្ទៀងផ្ទាត់ចំណូលចំណាយ ជាមួយធនាគារ សម្រាប់ឆ្នាំ២០២១-២០២២
- បើកថវិកាសម្រាប់ជួសជុលផ្លូវបន្ទាន់ ជំហាន៣ ឆ្នាំ២០២១ ជំហាន១,២ ឆ្នាំ២០២២
- បើកថវិកាសម្រាប់ជួសជុលផ្លូវប្រចាំ ជំហាន១,២ ឆ្នាំ២០២២
- បើកថវិកាសម្រាប់ជួសជុលផ្លូវខួប ជំហាន១,២ ឆ្នាំ២០២២
- បើកថវិកាសម្រាប់សាងសង់អណ្តូងជំហាន២ ឆ្នាំ២០២១,ជំហាន១,២ ឆ្នាំ២០២២
- បើកថវិកាក្រសួងសម្រាប់សាងសង់បង្គន់អនាម័យជំហាន១,២ ឆ្នាំ២០២២
- បិទបញ្ជីចំណូល-ចំណាយ និងបញ្ជីបេឡាប្រចាំខែ មករា-ធ្នូ ឆ្នាំ២០២២
- របាយការណ៍អាណាត្តិប្រចាំខែ មករា-ធ្នូ ឆ្នាំ២០២២
- របាយការណ៍កម្មវិធីចំណាយប្រចាំត្រីមាសទី១-៣ និងរបាយការណ៍កម្មវិធី ចំណាយប្រចាំឆ្នាំ២០២៣
- សំណើសុំសន្យាចំណាយលទ្ធកម្មប្រចាំឆ្នាំ និងលទ្ធកម្មកែតម្រូវប្រចាំ ឆ្នាំ២០២២
- រៀបចំឯកសារនីតិវិធីកិច្ចលទ្ធកម្ម ប្រចាំឆ្នាំ២០២២
- រៀបចំឯកសារនីតិវិធីកិច្ចលទ្ធកម្មកែតម្រូវ ប្រចាំឆ្នាំ២០២២
- រៀបចំឯកសាររដ្ឋទេយ្យបុរេប្រទាន លើកទី១ និងលើកទី២,៣,៤ ឆ្នាំ២០២២
- រៀបចំឯកសាបេសកកម្មទូទាត់ត្រង់ពីខែ មករា-តុលា ឆ្នាំ២០២២
- រៀបចំឯកសារទូទាត់ត្រង់ អគ្គីសនី,ទឹកស្អាត និងអ៊ិនធើណិត ឆ្នាំ២០២២
- រៀបចំឯកសារទូទាត់វគ្គបណ្តុះបណ្តាល គ.អ.ភ ប្រចាំឆ្នាំ២០២២
- រៀបចំទូទាត់ការប្រជុំផ្សព្វផ្សាយនិងដំណើការបោះឆ្នោតជ្រើសរើសប្រធានសហគមន៍កួយ ប្រចាំឆ្នាំ២០២២
- រៀបចំឯកសារទូទាត់ប្រជុំសិក្ខាសាលា ស្តីពីការលើកកម្ពស់អនាម័យដល់សហគមន៍
- ឯកសារទូទាត់ការប្រជុំផ្សព្វផ្សាយ ស្តីពីគោលការណ៍សហគមន៍សន្សំប្រាក់ ឆ្នាំ២០២២
- រៀបចំបញ្ជីសារពើភ័ណ្ឌ កើនឡើងថយចុះ ឆ្នាំ២០២១
- រៀបចំជម្រះបញ្ជីសារពើភ័ណ្ឌ សម្រាប់ ឆ្នាំ២០២២
- របាយការណ៍ឆ្លើយបំភ្លឺ ជូនចំពោះសវនកម្មជាតិ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១
- របាយការណ៍សមិតកម្ម សម្រាប់ត្រីមាសទី១-៣ ឆ្នាំ២០២២
- ប្រជុំសិក្ខាសាលា ស្តីពីការផ្សព្វផ្សាយទស្សនៈយេនឌ័រ ក្នុងវិស័យអភិវឌ្ឍន៍ជនបទ ឆ្នាំ២០២២
- ចូលរួមប្រជុំ ស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២២ នៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចូលរួមប្រជុំ ស្តីពី វគ្គបណ្តុះបណ្តាល ការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ( SARMIS )

- បានចូលរួមកិច្ចប្រជុំ ស្ដីពី ការរៀបចំគម្រោងស្នើសុំហិរញ្ញប្បទាន ឥតសំណងពីរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ សម្រាប់ឆ្នាំសារពើពន្ធ២០២៤ តាមប្រព័ន្ធវីដេអូ Microsoft Team។
- បានចូលរួមកិច្ចប្រជុំ ក្រុមប្រឹក្សាសកម្មភាពជនពិការ ខេត្តសៀមរាប តាមប្រព័ន្ធអនឡាញ (Zoom)
- បានចូលរួមកិច្ចប្រជុំសន្និបាត បូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅឆ្នាំ២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ តាមប្រព័ន្ធអនឡាញ
- ចូលរួមប្រជុំពិភាក្សាពិគ្រោះយោបល់ នឹងធ្វើផែនការយុទ្ធសាស្ត្រ ២០២៣-២០២៥
- ចូលរួមប្រជុំស្ដីពី ការផ្ទៀងផ្ទាត់ទិន្នន័យការអនុវត្តថវិកាតាមចំណាត់ថ្នាក់ភូមិសាស្ត្រ និងសេដ្ឋកិច្ច
- សិក្ខាសាលាស្ដីពី សារៈសំខាន់នៃការស្វែងយល់អំពីការវិនិយោគផ្នែកហិរញ្ញវត្ថុ
- ចូលរួមប្រជុំ ស្ដីពីការពន្លឿនការធ្វើប័ណ្ណកម្មសិទ្ធលើដីរដ្ឋ ដែលនៅសេសសល់
- បញ្ចូលរបាយការណ៍អនុវត្ត០៦ខែដើមឆ្នាំ ឆ្នាំ២០២២
- បញ្ចូលរបាយការណ៍អនុវត្ត០៩ខែដើមឆ្នាំ ឆ្នាំ២០២២
- បញ្ចូលរបាយការណ៍អនុវត្ត ប្រចាំឆ្នាំ២០២២
- រៀបចំផែនការថវិកា សម្រាប់ឆ្នាំ២០២៣
- រៀបចំផែនការយុទ្ធសាស្ត្រថវិកា សម្រាប់ឆ្នាំ២០២៣
- រៀបចំផែនការលទ្ធកម្ម ឆ្នាំ២០២២
- រៀបចំសំណើសុំបង្កើតតារាងរជ្ជទេយ្យបុរេប្រទាន ឆ្នាំ២០២៣
- រៀបចំស្នើសុំកែសម្រួលសមាភាពក្រុមលទ្ធកម្ម ឆ្នាំ២០២២
- រៀបចំធ្វើនិយ័តភាពផ្ទៃក្នុង

**ការងារសវនកម្ម និងអធិការកិច្ច**

- ចូលរួមទទួលសវនកម្មជាតិធ្វើអធិការកិច្ច សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១
- ចូលរួមទទួលសវនកម្មផ្ទៃក្នុងធ្វើអធិការកិច្ច សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១
- ចូលរួមទទួលអគារធិការធ្វើអធិការកិច្ច សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១
- ចូលរួមទទួលអគ្គនាយកដ្ឋានលទ្ធកម្ម សាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រួតពិនិត្យកិច្ចលទ្ធកម្ម តាមក្រោម សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១
- ចូលរួមទទួលសវនកម្មពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះធ្វើអធិការកិច្ចសម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០២១

**ការងារយេនឌ័រ**

- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយទស្សនៈយេនឌ័រក្នុងវិស័យអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព លោកជំទាវ ឡាយ វីរៈបុត្រ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប។
- ថ្នាក់ដឹកនាំ និងមន្ត្រីរាជការរបស់មន្ទីរ បានចូលរួមសិក្ខាសាលា ស្ដីពី ការផ្សព្វផ្សាយទស្សនៈយេនឌ័រក្នុងវិស័យអភិវឌ្ឍន៍ជនបទ នៅសាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទ

ខេត្តសៀមរាប ក្រោមអធិបតីភាព លោកជំទាវ ឡាយ វីរៈបុត្រ អនុរដ្ឋលេខាធិការ និងជាប្រធានក្រុមការងារយេនឌ័រ ក្រសួងអភិវឌ្ឍន៍ជនបទ។

- បានចូលរួមកិច្ចប្រជុំសាមញ្ញ លើកទី៣៧ ប្រចាំខែកក្កដាឆ្នាំ២០២២ របស់កម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក.) អាណត្តិទី៣
- បានចូលរួមសិក្ខាសាលាចែករំលែកបទពិសោធន៍នៃការអនុវត្តគម្រោងបញ្ជ្រាបយេនឌ័រសម្រាប់បង្កើតភាពអង់អាចដល់ស្ត្រី (PGM_WEE) នៅសណ្ឋាគារឆ្នេរសុខា ក្រុងព្រះសីហនុ។

**ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ**

- បានចូលរួមវគ្គបណ្តុះបណ្តាលអំពីគោលការណ៍ណែនាំ ស្តីពីការរៀបចំថវិកាសមិទ្ធកម្ម ឆ្នាំ២០២២ តាមប្រព័ន្ធអនឡាញ (Zoom)
- បានចូលរួមប្រជុំតាមអនឡាញ ស្តីពីការរៀបចំផែនការថវិកា និងផែនការយុទ្ធសាស្ត្រ,ពត៌មាន សមិទ្ធកម្ម ឆ្នាំ២០២៣-២០២៥
- ចូលរួមសិក្ខាសាលាស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ និងថវិកាសមិទ្ធកម្ម ឆ្នាំ២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

**២.ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍**

- ចុះធ្វើបច្ចុប្បន្នភាពផ្លូវជនបទ ២០ខ្សែផ្លូវ ប្រវែង ៣២៨.១០០មក្នុងស្រុក(ជីក្រែង, ស្វាយលើ,ពួក,អង្គរធំ,ក្រឡាញ់,អង្គរជុំ,ស្រីស្នំ,បន្ទាយស្រី,វ៉ារិន)។
- ចុះស្រង់ទិន្នន័យផ្លូវថ្មី ០៨ខ្សែ ប្រវែង ៤០.០០០មក្នុងស្រុក(ជីក្រែង,ស្វាយលើ,ពួក, ក្រឡាញ់,អង្គរជុំ,ស្រីស្នំ,បន្ទាយស្រី,វ៉ារិន)។
- ការងារថែទាំខួប ៖ ០៣ខ្សែ ប្រវែងសរុប ២៣.៤ គ.ម ក្រាលក្រួសក្រហម ស្ថិតក្នុងស្រុកស្រីស្នំ និងស្រុកជីក្រែង។
- ការងារជួសជុលបន្ទាន់៖ ០២កំណាត់ ប្រវែងសរុប ៥ គ.ម ក្រាលក្រួសក្រហម ស្ថិតក្នុងស្រុកស្រីស្នំ និង ស្រុកជីក្រែង ។
  ការងារថែទាំប្រចាំ ១៤ខ្សែប្រវែង២៤០.៥គ.ម
- ០៨ខ្សែ ប្រវែង ១១៥ គ.ម ក្រាលក្រួសក្រហម ស្ថិតក្នុងស្រុកអង្គរធំ ពួក ស្រីស្នំ ក្រឡាញ់ បន្ទាយស្រី សូទ្រនិគម ជីក្រែង និងស្រុកស្វាយលើ។
- ០៦ខ្សែ ប្រវែង ១២៥.៥ គ.ម ក្រាលកៅស៊ូពីរជាន់ ស្ថិតក្នុងស្រុកពួក អង្គរជុំ វ៉ារិន ស្រីស្នំ និងស្រុកសូទ្រនិគម ។
- ការចុះពិនិត្យស្ថានភាពផ្លូវដែលខូចខាតដោយសារគ្រោះទឹកជំនន់ មាន ១០ស្រុក ៤៩ឃុំ ២៨៨ភូមិ និងមានផ្លូវ ៥០ខ្សែ ប្រវែងសរុប ៥៦៥គម លិចទឹក ១១០គ.ម ទឹកហូរជាច់តួផ្លូវ ២៥គ.ម ច្រោះដើងទេ ៦៨.៥គ.ម។

**៣.ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

- បានចុះសិក្សាទីតាំងអណ្តូង ការបរិច្ចាកដីសម្រាប់សាងសង់អណ្តូងទឹក (អាហ្វ្រីដេស)

- សាងសង់អណ្តូងទឹកធន់នឹងការប្រែប្រួលអាកាសធាតុ (អាហ្វ្រីដេស) ចំនួន៖ ១៥ អណ្តូង ០៦ស្រុក ០៨ឃុំ ១៥ភូមិសម្រេចបាន១០០%។ បង្កើតគណៈកម្មការប្រើប្រាស់ទឹក, គណៈកម្មការថែទាំអណ្តូងទឹកស្អាតទាំង ១៥អណ្តូង។

**អត្រាគ្របដណ្តប់អនាម័យ**

- អត្រាគ្របដណ្តប់អនាម័យគិតត្រឹមឆ្នាំ២០២១ មានក្នុងកម្រិត ៨២.៩០% ក្នុងនោះចំនួនគ្រួសារដែលមានបង្គន់អនាម័យដែលមានការកែលម្អប្រើប្រាស់មានចំនួន ២០៧ ៨១៦ គ្រួសារ
- ស្រុកដែលបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាលមានចំនួន ២ស្រុក
- ឃុំដែលបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាលមានចំនួន ២៦ឃុំ
- ភូមិដែលបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាលមានចំនួន ៣៤០ភូមិ
- ចុះវាយតម្លៃ ODFភូមិ បានចំនួន៤៥លើក និង ODFឃុំ បានចំនួន៥ឃុំ និងODFស្រុក បានចំនួន០១ស្រុក ក្នុងស្រុកស្រីស្នំ ក្នុងស្រុកបន្ទាយស្រី ស្រុកវ៉ារិន ។

**ការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទថ្នាក់ខេត្ត (PWG)**

- PWG បានរៀបចំកិច្ចប្រជុំរបស់ខ្លួនប្រចាំត្រីមាស តាមរយៈកិច្ចប្រជុំផ្ទាល់ និងតាម online បានចំនួន ២លើក
- បានសម្របសម្រួលជូនអង្គការដៃគូអភិវឌ្ឍន៍នានាដែលធ្វើការងារលើផ្នែកទឹកស្អាត និងអនាម័យ ដើម្បីឱ្យការអនុវត្តការងារគ្រប់ដៃគូទាំងអស់បានប្រព្រឹត្តទៅដោយរលូន បានចំនួន ១៥អង្គការ

**ការកសាងសមត្ថភាពសហគមន៍**

- បានផ្តល់វគ្គបណ្តុះបណ្តាលស្តីពីសហគមន៍ដឹកនាំអនុវត្តអនាម័យដោយខ្លួនឯងដល់សហគមន៍ បានចំនួន ១៥វគ្គ មានអ្នកចូលរួម ៣២១នាក់ ស្រី ១៦៦នាក់ ។
- ចុះសម្របសម្រួល ការអនុវត្តសហគមន៍ដឹកនាំអនុវត្តអនាម័យដោយខ្លួនបានចំនួន ១០លើក មានអ្នកចូលរួមសរុប ចំនួន ៤១១នាក់ ស្រី ២៥៦នាក់ ។

**ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធអនាម័យ**

- ផ្តល់សម្ភារបង្គន់អនាម័យចំនួន ២០០ ដល់សហគមន៍ក្នុងឃុំវ៉ារិន ស្រុកវ៉ារិន និងឃុំរុនតាឯក ស្រុកបន្ទាយស្រី
- ចុះពិនិត្យ និងជំរុញការសាងសង់បង្គន់អនាម័យ ដែលគាំទ្រដោយមន្ទីរ នៅក្នុងឃុំវ៉ារិន និងឃុំរុន តាឯក បានចំនួន១១ លើក មានអ្នកចូលរួមសរុប ២១២នាក់ ស្រី ១២១នាក់ ។

**៤.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

- ខេត្តសៀមរាបមានប្រជាពលរដ្ឋជាជនជាតិដើមភាគតិចកួយ មួយក្រុមរស់នៅរាយប៉ាយក្នុងស្រុកវ៉ារិន ឃុំស្រែណូយចំនួន ០៧ភូមិ ដែលមានប្រជាពលរដ្ឋសរុប ៤៧០នាក់ ស្រី២៣៥នាក់ ស្មើនឹង១១៦គ្រួសារ។

- ចុះណែនាំនិងជំរុញការប្រមូលស្នាមមេដៃស្ដាំសមាជិកគ្រួសារនីមួយៗ(ទម្រង់គំរូទី៣, ទី៤ ដើម្បីសុំចូលសមាជិកសហគមន៍ជនជាតិដើមភាគតិច នៅភូមិគោលដៅ ឃុំស្រែណូយ ស្រុកវ៉ារិន។
- រៀបចំសំណុំបែបបទ ដើម្បីចុះឈ្មោះជ្រើសរើស ប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ (តំណាងសហគមន៍)
- ធ្វើសំណើសុំគោលការណ៍ចំណាយ សម្រាប់ផ្សព្វផ្សាយ និងដំណើរការបោះឆ្នោតជ្រើសរើសប្រធានសហគមន៍ជនជាតិដើមភាគតិច (ភូមិស្រែណូយ,ស្រែសមុទ្រ,និងវត្ត)ឃុំស្រែណូយ ស្រុកវ៉ារិន។
- ចូលរួមអបអរសាទរទិវាអន្តរជាតិជនជាតិដើមភាគតិច ពិភពលោកលើកទី២៨ និងលើកទី១៨នៅកម្ពុជា ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត សួស គង់** រដ្ឋលេខាធិកាប្រចាំការ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួង អភិវឌ្ឍន៍ជនបទ។
- ចូលរួមគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបាទសម្ដេចព្រះនរោត្តមសីហនុ ព្រះមហាវីរៈក្សត្រ ព្រះវររាជបីតា ឯករាជ្យបូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋគម្រប់ខួប១០ឆ្នាំ។
- ចូលរួមប្រជុំធ្វើផែនការសកម្មភាពអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងសិក្ខាសាលាតម្រង់ទិសស្ដីពីនីតិវិធី នៃការវាយតម្លៃ កំណត់អត្តសញ្ញាណក្រុមជនជាតិដើមភាគតិច និងបូកសរុបលទ្ធផលការងារជាមួយអង្គការដៃគូអភិវឌ្ឍន៍។

**៥.សមិទ្ធផលនៃការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការ**

**ការងារហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ**

គម្រោងផ្លូវDBST/WB

- ផ្លូវ DBST៤ខ្សែប្រវែង ៤៦.៨គ.ម អនុវត្តក្នុងស្រុកអង្គរជុំ,សូទ្រនិគម, ប្រាសាទបាគង, ជីក្រែង, វ៉ារិន សម្រេចបាន១០០%

គម្រោងសាច់ប្រាក់ពលកម្ម សម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទគាំទ្រដោយកសិករ៖

- ផ្លូវដីសរ ៤២ខ្សែប្រវែង ៨៧.៨គ.ម អនុវត្តក្នុងស្រុក ០៥ សម្រេចបាន ១០០%
- ផ្លូវក្រួសក្រហម ១០៧ខ្សែប្រវែង ៣៤០.៦គ.ម អនុវត្តក្នុងស្រុកទាំង១១ សម្រេចបាន ១០០%
- ផ្លូវដីស ៣៣ខ្សែប្រវែង ៦៩.៦គ.ម អនុវត្តក្នុងស្រុក០៥ សម្រេចបាន ១០០%
- សាងសង់បង្គន់សាធារណៈ១៣បង្គន់ ក្នុងស្រុកចំនួន ០៥សម្រេចបាន១០០%
- ផ្លូវក្រួសក្រហម ២៧ខ្សែ ប្រវែង ៦៩.៦គ.មអនុវត្តក្នុងស្រុក ០៥សម្រេចបាន១០០%

សហការណ៍ជាមួយគម្រោង ADB ដំហាន៣ បាច់៣អនុវត្តក្នុងស្រុកជីក្រែង ឃុំពង្រក្រោមមានភូមិ ១៣ភូមិ៖

- សាងសង់អណ្ដូងថ្មីអាហ្វ្រីដេសចំនួន៖ ១០០អណ្ដូង

- ផ្តល់ពាងត្រងទឹកភ្លៀងចំនួន៖ ៣៨៥២ពាង

  សហការណ៍ជាមួយគម្រោង Policy Matrix
- ជួសជុលអណ្តូងអាហ្វ្រីដេសចំនួន ៥០អណ្តូង
- យកសំណាកទឹកចំនួន ១០០អណ្តូងក្នុងស្រុក៥ ឃុំ១១ និងភូមិ៤៧
- បានសហការណ៍ជាមួយអង្គការក្រៅរដ្ឋាភិបាល ជ្រើសរើសទីតាំង សាងសង់អណ្តូង, សាងសង់ស្ថានីយ៍ដើម្បីផលិតទឹកកាដុង និងទីតាំងបណ្តាញចែកចាយទឹកក្នុងសហគមន៍ (ស្រុកពួក ក្រឡាញ់ វ៉ារិន ស្វាយលើ និងជីក្រែង)។ ក្នុងនោះដែរក៏បានបង្កើតគណៈកម្មការប្រើប្រាស់ និងថែទាំជួសជុលតាមទីតាំងនីមួយៗជាមួយអង្គការដៃគូ (ការីតាស ឡាយវ៉តធ័រ វើលវិសិន ភ្លែន និងទឹកស្អាត១០០១)។

**គម្រោង ឥណទានគាំទ្រសុខភាពសហគមន៍**

- អ្នកទទួលផលផ្តោតលើគ្រួសារក្រ១ក្រ២ ជាអាទិភាពទី១ប្រភេទក្រជម្មតា និងប្រជាពលរដ្ឋជីវភាពមធ្យមជាអាទិភាពបន្ទាប់ហើយមានគោលបំណង បង្កើនកម្រិតជីវភាព និងបង្កើតមុខរបរដើម្បីរកប្រាក់ចំណូលបន្ថែមសំរាប់គ្រួសារជនបទ។
- ការចុះបញ្ចេញទុនឱ្យខ្ចី ជាសាច់ប្រាក់ដោយមានការប្រាក់១.៥% បរិមាណទុនកម្ចីពី៥០០ ០០០៛ ទៅ១ ០០០ ០០០៛ ការសងការប្រាក់រៀងរាល់ខែ និងប្រាក់ដើមសងត្រឡប់តាមលទ្ធភាព(មិនកំណត់ទំហំនិងពេលវេលា)។ ដែលមានស្រុកគោលដៅចំនួន០២ស្រុក ០២ឃុំ ០២ភូមិ (ស្រុកក្រឡាញ់ និងស្រុកបន្ទាយស្រី ០២ភូមិ ភ្នំទ្រង់បាត និងថ្នល់ទទឹង)។
- សហការណ៍ជាមួយគម្រោងអាគ្រីស៊ីតដាក់ប្រាក់សន្សំចំនួន ១០ក្រុម នៅសង្កាត់ក្របីរៀលមានចំនួន ០៧ភូមិ និងឃុំពួកចំនួន ០៣ភូមិ ដែលមានសមាជិក សរុបចំនួន ៦៧០ នាក់ ស្រី ៥៧៥នាក់ (បង់ប្រាក់សន្សំប្រចាំខែ បង់ការប្រាក់ប្រចាំខែ ផ្តល់ប្រាក់ឱ្យសមាជិកខ្ចី និងប្រមូលប្រាក់ដើម)។

## II.**បញ្ហាប្រឈម**

- សហគមន៍ខ្វះការយកចិត្តទុកដាក់ថែរក្សាសំណង់ផ្គត់ផ្គង់ទឹកជនបទ
- ការយល់ដឹងពីសារៈសំខាន់ទឹកស្អាត និងអនាម័យរបស់សហគមន៍នៅមានកម្រិត
- តម្រូវការសម្រាប់ការអភិវឌ្ឍច្រើន ថវិកាគាំទ្រនៅមានកម្រិត
- ខ្វះការចូលរួមថែទាំសមិទ្ធផលនានារបស់វិស័យអភិវឌ្ឍន៍ជនបទ
- ប្រជាពលរដ្ឋមួយចំនួនមិនទាន់យល់ពីអនាម័យ និងធ្វើការផ្លាស់ប្តូរទំលាប់
- ប្រជាជនធ្វើការចំណាកស្រុកច្រើន
- ផ្លូវជនបទរងការខូចខាតដោយសារគ្រោះទឹកជំនន់ច្រើនជារៀងរាល់ឆ្នាំ

## III.**ទិសដៅការងារឆ្នាំ២០២៣**

### ១.ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

**ការងាររដ្ឋបាលនិងបុគ្គលិក**

- ជំរុញការងារគ្រប់គ្រងលិខិតបទដ្ឋាន និងការងារជំឡើងកាំប្រាក់ដល់មន្ត្រីរាជការដែលមានស្នាដៃ និងតាមដានបញ្ជីវត្តមានជាប្រចាំ
- គ្រប់គ្រងលិខិតចេញ-ចូលរបស់មន្ទីរ

**ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បណ្តុះបណ្តាលជំនាញជួសជុលគ្រឿងយន្តកសិកម្មខ្នាតតូចចំនួន០២វគ្គ ឃុំស្វាយសរ ស្រុកវ៉ារិន និងឃុំត្រំពាំងធំ ស្រុកប្រាសាទបាគង។
- បណ្តុះបណ្តាលជំនាញដំណាំគ្រួសារ និងជីកំប៉ុស្ត ១វគ្គ ស្រុកប្រាសាទបាគង
- បន្តរៀបចំផែនការសម្រាប់បណ្តុះបណ្តាល ដល់មន្ត្រីរាជការបន្ថែមទៀត

**ការងារផែនការ**

- ត្រួតពិនិត្យនិងតាមដានផែនការដែលបានលើកឡើង
- បន្តធ្វើរបាយការណ៍បូកសរុបលទ្ធផលការងាររបស់មន្ទីរ ជាប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ២០២៣
- ធ្វើផែនការការងារ០៣ឆ្នាំរំកិល ជូនសលាខេត្ត
- ធ្វើផែនការការងាររបស់មន្ទីរសម្រាប់ឆ្នាំ២០២៣

**ការងារផ្គត់ផ្គង់ហិរញ្ញវត្ថុ**

- រៀបចំឯកសារបើកប្រាក់បៀវត្ស ជូនមន្ត្រីរាជការ
- សម្របសម្រួលជំពូកថវិកា និងរាល់ការចំណាយរបស់មន្ទីរ
- ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាព
- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ
- អនុវត្តផែនការលទ្ធកម្ម។

**ការងារយេនឌ័រ**

- ចូលរួមរៀបចំពិធីអបអរសាទរទិវាអន្តរជាតិនារី ០៨មីនា ឆ្នាំ២០២៣
- ចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ (គ.ក.ស.ក)

**២.ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍**

**ការងាររៀបចំបញ្ជីសារពើភ័ណ្ឌ និងទិន្នន័យផ្លូវជនបទ**

- ចុះប្រមូលទិន្នន័យ និងបញ្ជីសារពើភ័ណ្ឌផ្លូវជនបទក្នុងខេត្ត
- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យផ្លូវជនបទ។

**ការងារថែទាំផ្លូវជនបទ**

- ជួសជុលផ្លូវក្រួសក្រហម ០១ខ្សែប្រវែង ១០ ០០០ម ទទឹង ៦មដែលស្ថិតនៅភូមិគោកយាង និងភូមិតាប៉ាង ឃុំសែនសុខ ស្រុកក្រឡាញ់ ខេត្តសៀមរាប។
- រៀបចំបញ្ជីសារពើភ័ណ្ឌ និងស្រង់ទិន្នន័យផ្លូវជនបទ

**៣.ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

**ការងារសាងសង់អណ្តូងទឹកធន់នឹងការប្រែប្រួលអាកាសធាតុ**

- សាងសង់អណ្តូងអាហ្វ្រីដេសចំនួន១៧អណ្តូង នៅស្រុកពួក ស្រុកវ៉ារិន ស្រុកបន្ទាយស្រី និងស្រុកប្រសាទបាគង
- ជំរុញផ្សព្វផ្សាយស្តីពីការទុកដាក់ទឹក និង ការប្រើប្រាស់ទឹកសុវត្ថិភាព

**ការងារសាងសង់បង្គន់អនាម័យជនបទ**

- ចុះជំរុញការសាងសង់បង្គន់នៅតាមខ្នងផ្ទះរបស់សហគមន៍
- ផ្តល់សម្ភារសាងសង់បង្គន់អនាម័យ នៅតាមភូមិ ឃុំគោលដៅ
- ផ្តល់វគ្គបណ្តុះបណ្តាលដល់សហគមន៍ស្តីពីការគ្រប់គ្រងកាកសំណល់លាមក
- ពង្រឹងយន្តការPWG នៅគ្រប់ភូមិ ឃុំ ស្រុក ក្នុងខេត្ត
- រៀបចំកិច្ចប្រជុំនៅតាមស្រុកក្នុងខេត្ត ដើម្បីជំរុញផែនការ ODF ឆ្នាំ២០២៣ ស្រុកដែលត្រូវសម្រេចជាស្រុកបញ្ចប់ការបន្ទោបង់ពាសវាលពាសកាលមានចំនួន៤ ស្រុក គឺ ស្រុកបន្ទាយស្រី ស្រុកជីក្រែង ស្រុកក្រឡាញ់ និង ក្រុងសៀមរាប
- ឆ្នាំ២០២៤ស្រុកដែលត្រូវសម្រេចជាស្រុកបញ្ចប់ការបន្ទោបង់ពាសវាលពាសកាលមាន ចំនួន៤ ស្រុក គឺ ស្រុកប្រាសាទបាគង ស្រុកសូទ្រនិគម ស្រុកអង្គរធំ និង ស្រុកពួក
- ឆ្នាំ២០២៥ស្រុកដែលត្រូវសម្រេចជាស្រុកបញ្ចប់ការបន្ទោបង់ពាសវាលពាសកាលមាន ចំនួន២ ស្រុក គឺ ស្រុកវ៉ារិន និង ស្រុកស្វាយលើ

**៤.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

**ការងារអភិវឌ្ឍន៍ និងអភិរក្សជនជាតិដើមភាគតិច**

- ចុះជំរុញការប្រមូលស្នាមមេដៃខាងស្តាំសមាជិកគ្រួសារនីមួយៗ( ទំរង់គំរូទី៣,៤ )
- រៀបចំសំណុំបែបបទដើម្បីសុំជាសមាជិកសហគមន៍ជនជាតិដើមភាគតិចក្នុយឃុំស្រែណូយ ស្រុកវ៉ារិន។
- រៀបចំសំណើដើម្បីស្នើសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ពីក្រសួងអភិវឌ្ឍន៍ជនបទ។

**ការងារលើកកម្ពស់កំណើនសេដ្ឋកិច្ចគ្រួសារនៅជនបទ**

- រៀបចំគម្រោងបណ្តុះបណ្តាលគ្រោះមហន្តរាយ (លើកកម្ពស់ ការយល់ដឹង របស់ប្រជាពលរដ្ឋ ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ នៅសហគមន៍ និង ភាពបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ)
- នៅស្រុកអង្គរជុំ ខេត្តសៀមរាប ចំនួន០៤វគ្គ ដែលមានសិក្ខាកាមចូលរួម ១០០នាក់
- រៀបចំគម្រោងអភិវឌ្ឍន៍ភូមិចម្រុះ (ការធ្វើឱ្យប្រសើរឡើងនូវជីវភាព របស់សហគមន៍មូលដ្ឋាន) ចំនួន ០១ភូមិ នៅស្រុកបន្ទាយស្រី ខេត្តសៀមរាប លើកសិករចំនួន ១០០ គ្រួសារ ។
- រៀបចំគម្រោងសន្តិសុខស្បៀង (ការបង្កើនចំណូលរបស់គ្រួសារក្រីក្រ និងអាហារមិនប៉ះពាល់ដល់សុខភាព) ស្រុកប្រាសាទបាគង ខេត្តសៀមរាប ចំនួន ០៤វគ្គ លើកសិករចំនួន ៨០ គ្រួសារ ។

- រៀបចំគម្រោងបើកសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ) ស្រុកស្រីស្នំ និងស្រុកវ៉ារិន ខេត្តសៀមរាប ចំនួន ១០វគ្គ សិក្ខាកាមសរុប ២៥០នាក់។

**៥.សមិទ្ធផលនៃការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការ**

- គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ(RID4CAM) ប្រវែង ១២៧គ.ម ស្ថិតក្នុងស្រុកស្រីស្នំ ស្រុកអង្គរធំ ស្រុកអង្គរជុំ ស្រុកពួក ស្រុកបន្ទាយស្រី ស្រុកជីក្រែង និងប្រាសាទបាគង។
- គម្រោងខ្សែច្រវ៉ាក់តម្លៃកសិកម្ម និងលើកកម្ពស់សុវត្ថិភាព(ADB) ប្រវែង ១៦.២គ.ម ស្ថិតក្នុងស្រុកអង្គរជុំ។

IV.**សន្និដ្ឋាន**

សមិទ្ធផលដែលសម្រេចបានក្នុងឆ្នាំ២០២២ នេះ គឺពិតជាបានធ្វើឱ្យការអភិវឌ្ឍន៍ក្នុងមូលដ្ឋានមានសន្ទុះប្រែប្រួល យ៉ាងឆាប់រហ័សទាំងផ្នែកសង្គមកិច្ច និងផ្នែកសេដ្ឋកិច្ច ជាពិសេសជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ កាន់តែមាន ភាពប្រសើរឡើងជាលំដាប់។ ការងារផ្លូវជនបទកាន់តែត្រូវបានពង្រីកទៅតាមតំបន់ដាច់ស្រយាល ធ្វើឱ្យទីក្រុង និងជនបទកាន់តែខិតជិតគ្នា ព្រមទាំងធ្វើឱ្យការទំនាក់ទំនង កាន់តែមានភាពងាយស្រួលឡើង។ ការងារផ្គត់ផ្គង់ទឹកជនបទពិតមែនតែជួបការលំបាកខ្លះ ប៉ុន្តែយើងបានកំពុងបន្តសាងសង់អណ្តូងបន្ថែមទៀតក្នុងតំបន់នោះ រួមទាំងការអប់រំលើការ ប្រើប្រាស់ទឹកសុវត្ថិភាព និងអនាម័យឱ្យកាន់តែស៊ីជម្រៅ និងកាន់តែទូលំទូលាយ ទៅតាមតំបន់ជនបទ។ យើងបានយកចិត្តទុកដាក់ ក្នុងការបណ្តុះបណ្តាលគណៈកម្មការអភិវឌ្ឍន៍ភូមិឱ្យចេះរៀបចំផែនការអភិវឌ្ឍន៍ភូមិ និងធ្វើឱ្យសហគមន៍កាន់តែមានស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការការពារ និងថែទាំសមិទ្ធិផល ដែលមានក្នុង មូលដ្ឋានឱ្យកាន់តែប្រសើរឡើង ។

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប នៅតែបន្ត និងពង្រីកបន្ថែម នូវបេសកកម្មរបស់ខ្លួន ដើម្បីឆ្លើយតបនឹងផែនការយុទ្ធសាស្ត្ររបស់ក្រសួង និងស្របតាមគោលនយោបាយយុទ្ធសាស្ត្រ និងវិធានការណ៍នានារបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា។

ថ្ងៃ.................................ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

សៀមរាប, ថ្ងៃទី...................ខែ..................ឆ្នាំ ២០២២

**ប្រធានមន្ទីរ**